**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែប្រែមាត្រា ៤នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- តាមសំណើរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

## ស ម្រេ ច

**មាត្រា ១ .-**

មាត្រា ៤នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវបានកែប្រែដូចខាងក្រោម :

មាត្រា ៤ ថ្មី : ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានសមាសភាពដូចតទៅ :

- ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធាន
- អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ អនុប្រធាន
- រដ្ឋមន្ត្រី នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុប្រធាន
- រដ្ឋលេខាធិការ នៃក្រសួងអភិវឌ្ឍន៍ជនបទ អនុប្រធាន
- រដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិកអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- រដ្ឋលេខាធិការ នៃទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងការពារជាតិ សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងពាណិជ្ជកម្ម សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងផែនការ សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងបរិស្ថាន សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងធនធានទឹក និងឧតុនិយម សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងព័ត៌មាន សមាជិក
- រដ្ឋលេខាធិការ នៃក្រសួង យុត្តិធម៌ សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងទេសចរណ៍ សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី សមាជិក
- ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា សមាជិក
- តំណាងក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សមាជិក
- អគ្គលេខាធិការ គណៈកម្មការជាតិវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

**មាត្រា ២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងសមាជិកទាំងអស់នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដូចមានសមាសភាពចែងក្នុងមាត្រា ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ជ.ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

អនុប្រធានអចិន្ត្រៃយ៍

**សុខ អាន**

<ins>កន្លែងទទួល</ins> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង និងស្ថាប័ន
- ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ដូចមាត្រា ៣
- ឯកសារ - កាលប្បវត្តិ